# លដុកិកជាតក




*ព្រះសាស្តាកាលស្តេចគង់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **វន្ទាមិ តំ កុញ្ជរ សដ្ឋិហាយនំ** *ដូច្នេះជាដើម ។*

*សេចក្តីសង្ខេបថា ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយញុំាងកថាឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ ទេវទត្តជាមនុស្សរបឹងរឹងរូស អាក្រក់ មានការគំរាមកំហែង មិនមានសេចក្តីករុណា សូម្បីត្រឹមតែក្នុងសត្វទាំងឡាយ ។ ព្រះសាស្តាយាងមក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយសន្ទនាគ្នា ដោយរឿងអ្វី ? កាលភិក្ខុទាំងឡាយទូលថា ដោយរឿងឈ្មោះនេះ ព្រះពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែ*

*ក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ជាមនុស្សមិនមានករុណាដែរ ដូច្នេះហើយ ព្រះអង្គនាំអតីតនិទានមកថា ៖*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត ធ្វើរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតដំរី កាលចម្រើនវ័យធំហើយ ជាសត្វមានកាយធំ គួរជាទីនាំមកនូវសេចក្តីជ្រះថ្លា មានដំរី ៨ ម៉ឺនជាបរិវារ បានជាអធិបតីលើហ្វូងដំរី ត្រាច់រស់នៅក្នុងហិមវន្តប្រទេស ។ ក្នុងគ្រានោះ មានមេចាបចៀបកប្បាសមួយដាក់ចុះពងក្នុងទីត្រាច់ទៅរបស់ដំរី ពងទាំងឡាយកាលគ្រប់ខែចាស់ហើយ ក៏បែក កើតចេញជាកូនចាប ។ កូនចាបទាំងនោះ កាលស្លាបទាំងឡាយមិនទាន់ចម្រើនដុះរោមពេញ មិនអាចនឹងហើរទៅណាបានឡើយ ព្រះមហាសត្វមានពួកដំរី ៨ ម៉ឺនជាបរិវារ កាលត្រាច់ស្វែងរកអាហារ ក៏ដល់កន្លែងចាបនោះ ។ មេចាបចៀបកប្បាសឃើញហ្វូងដំរីហើយគិតថា ស្តេចដំរីនេះនឹងជាន់សម្លាប់កូន របស់យើងណ្ហើយចុះ យើងនឹងសូមនូវការរក្សាដែលប្រកបដោយធម៌ ដើម្បីប្រយោជន៍ដល់ការ ការពារកូនទាំងឡាយ នឹងស្តេចដំរីនោះ ។ មេចាបចៀបកប្បាសនោះ ធ្វើស្លាបទាំងពីរឲ្យផ្គុំចូលគ្នាបិតនៅខាងមុខស្តេចដំរីហើយពោលគាថាទី ១ ថា*

**វន្ទាមិ តំ កុញ្ជរ សដ្ឋិហាយនំ, អារញ្ញកំ យូថបតឹ យសស្សឹ;**
**បក្ខេហិ តំ បញ្ជលិកំ ករោមិ, មា មេ វធី បុត្តកេ ទុព្ពលាយ ។**

***ខ្ញុំសូមថ្វាយបង្គំលោក ជាដំរីមានកម្លាំងខ្សោយក្នុងកាលមានអាយុ ៦០ ជាអ្នកនៅក្នុងព្រៃ ជាម្ចាស់ហ្វូង មានយស ខ្ញុំសូមធ្វើនូវអញ្ជលិកម្ម ចំពោះលោក ដោយស្លាបទាំងឡាយ សូមកុំឲ្យលោកសម្លាប់កូនរបស់ខ្ញុំ ជាសត្វមាន កម្លាំងខ្សោយ ។***

*បណ្តាបទទាំងនោះ បទថា* **សដ្ឋិហាយនំ** *សេចក្តីថា មានកម្លាំងខ្សោយ ក្នុងកាលដែលមានអាយុ ៦០ ឆ្នាំ ។ បទថា* **យសស្សឹ** *សេចក្តីថា ដល់ព្រមដោយបរិវារ ។ បទថា* **បក្ខេហិ តំ បញ្ជលិកំ ករោមិ** *សេចក្តីថា ខ្ញុំសូមធ្វើអញ្ជលិកម្មសំពះលោកដោយស្លាប ។*

*ព្រះមហាសត្វពោលថា នែមេចាបចៀបកប្បាស នាងកុំគិតច្រើនអី យើងនឹងរក្សាកូនរបស់នាង ដូច្នេះហើយ ទើបឈរនៅខាងលើកូនចាបទាំងនោះ កាលដំរី ៨ ម៉ឺនទៅផុតហើយ ព្រះពោធិសត្វប្រាប់មេចាបចៀបកប្បាសថា នែមេចាបចៀបកប្បាស មានដំរីមួយត្រាច់ដើរតែឯង នឹងមកតាមក្រោយពួកយើង ដំរីនោះមិនធ្វើតាមពាក្យយើងទេ កាលដំរីនោះមក នាងចូរសូមអង្វរដំរីនោះ ឲ្យគេធ្វើសេចក្ដីសួស្ដីដល់កូននាងចុះ ពោលយ៉ាងនេះហើយ ស្ដេចដំរីក៏ចៀសចេញទៅ ។ ចំណែកមេចាបចៀបកប្បាសធ្វើការក្រោកទទួលដំរីនោះ ធ្វើអញ្ជលីសំពះដោយស្លាបទាំងពីរ ហើយពោលគាថាទី ២ ថា*

**វន្ទាមិ តំ កុញ្ជរ ឯកចារឹ, អារញ្ញកំ បព្ពតសានុគោចរំ;**
**បក្ខេហិ តំ បញ្ជលិកំ ករោមិ, មា មេ វធី បុត្តកេ ទុព្ពលាយ ។**

***ខ្ញុំសូមថ្វាយបង្គំលោក ជាដំរីត្រាច់ទៅតែម្នាក់ឯង ជាអ្នកនៅក្នុងព្រៃ ដើរទៅតាមញកភ្នំ ខ្ញុំសូមធ្វើអញ្ជលិកម្ម ដោយស្លាបទាំងឡាយ សូមលោកកុំសម្លាប់កូនខ្ញុំ ជាសត្វមានកម្លាំងខ្សោយ ។***

*បណ្ដាបទទាំងនោះ បទថា* **បព្ពតសានុគោចរំ** *សេចក្ដីថា អ្នកត្រាច់ស្វែងរកអាហារតាមយនសេលបព៌ត (ភ្នំគំនរថ្ម) និងបំសុបព៌ត (ភ្នំធូលីដី)។*

*ដំរីនោះស្ដាប់ពាក្យមេចាបហើយ ពោលគាថាទី ៣ ថា*

**វធិស្សាមិ តេ លដុកិកេ បុត្តកានិ, កិំ មេ តុវំ កាហសិ ទុព្ពលាសិ;**
**សតំ សហស្សានិបិ តាទិសីនំ, វាមេន បាទេន បពោថយេយ្យំ ។**

***នែមេចាបចៀបកប្បាស អញនឹងសម្លាប់នូវកូននាង នាងជាសត្វមានកម្លាំងខ្សោយ នឹងធ្វើអ្វីដល់អញ អញនឹងជាន់នូវចាបសូម្បីមួយសែន ប្រហែលនឹងនាងឯងដោយជើងឆ្វេង ។***

*បណ្ដាបទទាំងនោះ បទថា* **វធិស្សាមិ តេ** *សេចក្ដីថា ដំរីពោលថា ព្រោះហេតុអ្វី បានជានាងទុកកូនលើផ្លូវជាទីត្រាច់ទៅរបស់យើង នាងទុកកូននោះ ព្រោះហេតុណា ព្រោះហេតុ*

នោះ យើងនឹងសម្លាប់កូនរបស់នាង ។ បទថា **កឹំ មេ តុវំ កាហាសិ** សេចក្តីថា នាងមានកម្លាំងខ្សោយនឹងធ្វើអ្វី ដល់យើងដែលមានកម្លាំងច្រើន ។ បទថា **បទោជយេយ្យំ** សេចក្តីថា យើងជាន់ឈ្លីនូវចាបសូម្បីមួយសែន ដែលដូចជានាង ដោយជើងឆ្វេង ចាំបាច់ពោលថ្វីដល់ជើងស្តាំងនោះ ។

ដំរីនោះពោលយ៉ាងនេះហើយ ក៏ដើរជាន់កូនរបស់មេចាបចៀបកប្បាស ដោយជើងបន្ទាបង់មូត្រ រួចស្រែកឡើង ហើយចៀសចេញទៅ ។ មេចាបពួនសម្ងំលើមែកឈើ ពោលថា នៃដំរី ឥឡូវនេះ អ្នកស្រែកហើយទៅ ពីរបីថ្ងៃទៀត អ្នកនឹងឃើញការធ្វើរបស់យើង អ្នកមិនដឹងភាពធំនៃកម្លាំងបញ្ញាជាងកម្លាំងកាយ យើងនឹងឲ្យអ្នកបានដឹង ដូច្នេះកាលនឹងគំរាមទើបពោលគាថាទី ២ ថា

**ន ហេវ សព្វត្ថ ពលេន កិច្ចំ, ពលញ្ហិ ពាលស្ស វធាយ ហោតិ;**
**ករិស្សាមិ តេ នាគរាជា អនត្ថំ, យោ មេ វធី បុត្តកេ ទុព្វលាយ ។**

***កិច្ចដោយកម្លាំងកាយ មិនមែនប្រើបានគ្រប់កន្លែងទេ ព្រោះកម្លាំងកាយ សម្លាប់បានតែអ្នកល្ងង់ទេ នៃស្តេចដំរី អ្នកណាសម្លាប់កូនរបស់យើង ជាសត្វមានកម្លាំងថយ យើងនឹងធ្វើនូវសេចក្តីវិនាស ដល់អ្នកនោះវិញ ។***

បណ្តាបទទាំងនោះ បទថា **ពលេន** បានដល់ ដោយកាយពល ។ បទថា **អនត្ថំ** សេចក្តីថា សេចក្តីមិនចម្រើន ។ បទថា **យោ មេ** សេចក្តីថា អ្នកណាជាអ្នកសម្លាប់កូនយើងដែលមានកម្លាំងខ្សោយ ។

មេចាបពោលយ៉ាងនេះហើយ ក៏ចូរទៅបម្រើក្អែកមួយ អស់ពីរបីថ្ងៃ ក្អែកនោះកាលមានចិត្តត្រេកអរទើបពោលថា តើយើងនឹងធ្វើអ្វីដល់នាង ។ មេចាបចៀបកប្បាសពោលថា បពិត្រលោកម្ចាស់ កិច្ចដទៃមិនមានដល់ខ្ញុំទេ ខ្ញុំប្រាថ្នាសូមឲ្យលោកម្ចាស់ចឹកបំបែកភ្នែកទាំងពីររបស់ដំរីដែលត្រាច់ដើរតែឯងមួយនោះដោយចំពុះ ។ ក្អែកទទួលថា ល្អហើយនាង ។ មេ

ចាបនោះបានទៅបម្រើរុយក្បាលខៀវមួយ ។ សូម្បីរុយក៏ពោលថា តើយើងនឹងធ្វើអ្វីដល់នាង មេចាបពោលថា កាលក្អែកចឹកបំបែកភ្នែករបស់ដំរីដែលត្រាច់ទៅតែឯងនោះហើយ ខ្ញុំប្រាថ្នាឲ្យលោកពងដាក់ភ្នែកដំរីនោះ រុយទទួលថា ល្អណាស់នាង បន្ទាប់មក មេចាបក៏ចូលទៅបម្រើកង្កែបមួយ កង្កែបនោះពោលថា យើងនឹងធ្វើអ្វីដល់នាង មេចាបចៀបកប្បាសពោលថា ក្នុងកាលណា ដំរីដែលត្រាច់ទៅតែឯងនោះខ្វាក់ភ្នែក កំពុងស្វែងរកទឹកផឹក ក្នុងកាលនោះ លោកចូរទៅឋិតនៅលើកំពូលភ្នំ ហើយធ្វើសំឡេង កាលដំរីនោះឡើងទៅកាន់កំពូលភ្នំ លោកចូរចុះមក ធ្វើសំឡេងត្រង់ជ្រោះភ្នំ ខ្ញុំប្រាថ្នាមានប្រមាណប៉ុណ្ណោះអំពីសម្នាក់លោក ។ សូម្បីកង្កែបក៏ទទួលពាក្យរបស់មេចាបនោះថា ល្អ ។

លំដាប់នោះ ថ្ងៃមួយ ក្អែកក៏ទៅចឹកបំបែកភ្នែកទាំងពីររបស់ដំរីដោយចំពុះ ហើយរុយក្បាលខៀវក៏មកពងដាក់ ។ ដំរីនោះប្រឫល់ដោយដង្កូវទាំងឡាយ ក៏ដល់ទុក្ខវេទនា កាលស្រេកទឹកខ្លាំង ទើបត្រាច់ស្វែងរកទឹកផឹក ។ ក្នុងកាលនោះ កង្កែបបានឋិតនៅលើកំពូលភ្នំ ក៏ធ្វើសំឡេងឡើង ។ ដំរីគិតថា ទឹកផឹកនឹងមានក្នុងទីនោះ ទើបឡើងទៅកាន់កំពូលភ្នំ ។ គ្រានោះ កង្កែបចុះទៅឋិតនៅត្រង់ជ្រោះភ្នំ ហើយធ្វើសំឡេង ។ ដំរីគិតថា ទឹកផឹកនឹងមានក្នុងទីនោះ ដូច្នេះហើយ មានមុខបែរទៅរកជ្រោះភ្នំ កាលដើរទៅ ក៏ភ្ទាត់ធ្លាក់ រមៀលចុះមកកាន់ជើងភ្នំ ហើយបានដល់ការអស់ជីវិតទៅ ។ មេចាបចៀបកប្បាសបានដឹងមរណភាពរបស់ដំរីនោះហើយ មានចិត្តត្រេកអរថា យើងនឹងឃើញខ្នងសត្រូវ ដូច្នេះទើបដើរចង្រ្កមលើកដំរីនោះ (ចំណេរកាលតទៅ) ក៏ទៅតាមយថាកម្ម ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ពៀរវេរា គឺបុគ្គលមិនគប្បីធ្វើមួយអន្លើដោយអ្នកណាមួយឡើយ ដំរីសូម្បីមានកម្លាំងយ៉ាងនេះ ក៏ត្រូវជនទាំង ៤ ដែលរួមគ្នាតែមួយ ធ្វើឲ្យអស់ជីវិតដល់ដំរីនោះ ដូច្នេះហើយ ទ្រង់ត្រាស់អភិសម្ពុទ្ធគាថា និងប្រជុំជាតកថា

**កាកញ្ច បស្ស លដុកិកំ, មណ្ឌូកំ នីលមក្ខិកំ;**
**ឯតេ នាគំ អឃាតេសុំ, បស្ស វេរស្ស វេរិនំ;**

**តស្មា ហិ វេរំ ន ករេយ្យាថ,          អប្បិយេនបិ កេនចិ ។**

*អ្នកចូរមើលនូវក្អែក ចាបចៀបកប្បាស កង្កែបនិងរុយខៀវ សត្វទាំងនុ៎ះ សម្លាប់នូវដំរីបាន អ្នកចូរមើល (នូវគតិ) នៃពៀររបស់ពួកសត្វមានពៀរ ព្រោះហេតុនោះ អ្នកទាំងឡាយ កុំធ្វើនូវពៀរ នឹងជនណាមួយ សូម្បីមិនជាទីស្រឡាញ់ឡើយ ។*

*បណ្ដាបទទាំងនោះ បទថា* **បស្ស** *សេចក្ដីថា ជាពាក្យហៅដោយមិនកំណត់ តែព្រោះត្រាស់សំដៅយកពួកភិក្ខុ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើល ។ ពាក្យថា* **ឯតេ** *សេចក្ដីថា សត្វទាំង៤នោះ រួមគ្នាជាមួយ ។ បទថា* **អឃាតេសុំ** *សេចក្ដីថា នាំគ្នាសម្លាប់ដំរីនោះ ។ បទថា* **បស្ស វេរស្ស វេរិនំ** *សេចក្ដីថា អ្នកទាំងឡាយចូរមើលគតិនៃពៀររបស់អ្នកមានពៀរ ។*

**តទា ឯកចារិកហត្ថី ទេវទត្តោ អហោសិ** *ដំរីដែលត្រាច់ដើរតែឯង ក្នុងកាលនោះ បានមកជាទេវទត្ត*

**យូថបតិ បន អហមេវ អហោសិំ** *ចំណែកដំរីមេហ្វូង គឺតថាគត នេះឯង ។*

*លដុកិកជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បញ្ចកនិបាត មណិកុណ្ឌលវគ្គ បិដកលេខ ៥៩ ទំព័រ ១០)*

*ថ្ងៃអង្គារ ១៣ រោច ខែបឋមាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១០ ខែ កក្កដា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*